# សេចក្តីប្រកាសព័ត៌មាន

កាលពីព្រឹកថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ ២០០៩ វេលាម៉ោង ៦:៣០នាទី នាទីស្តីការក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ មានប្រារព្ធពិធីក្រុងពាលី និងបញ្ចុះបឋមសីលាតាមផ្លូវប្រពៃណីសាសនាដើម្បីបើកការដ្ឋានស្ថាបនាអគារទីស្តីការក្រសួងនេះ និងមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីរាជធានីភ្នំពេញជាថ្មីឡើងវិញ។ អង្គពិធីបានព្រឹត្តទៅក្រោមអធិបតីភាព ឯកឧត្តមទេសរដ្ឋមន្ត្រី អ៊ឹម ឈុនលឹម រដ្ឋមន្ត្រីក្រសួងរៀបចំ ដែនដី នគរូបនីយកម្ម និងសំណង់និងលោកជំទាវ និងដោយមានព្រះរាជវត្តមានរបស់ សម្តេចព្រះសុមេធាធិបតី នន្ទ ង៉ែត ព្រះសង្ឃនាយកនៃព្រះរាជាណាចក្រកម្ពុជា។ អញ្ជើញចូលរួមក្នុងឱកាសនេះ មានវត្តមានឯកឧត្តម លោកជំទាវ លោក លោកស្រី ជារដ្ឋលេខាធិការ អនុរដ្ឋលេខាធិការអគ្គនាយក ថ្នាក់ដឹកនាំគ្រប់ថ្នាក់ និងមន្ត្រីរាជការនៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីរាជធានីភ្នំពេញ សរុបមានប្រមាណ ២០០នាក់។

បន្ទាប់ពីបានដំណើរការតាមប្រពៃណីសាសនា នូវពិធីក្រុងពាលីរួចមក ឯកឧត្តមទេសរដ្ឋមន្ត្រី អ៊ឹម ឈុនលឹម និងលោកជំទាវ អមដំណើរដោយអ្នកចូលរួមទាំងអស់ បានអញ្ជើញបញ្ចុះបឋមសីលា និងបញ្ចោគ្រឿងចក្រខួងរណ្តៅគ្រឹះអគារ ជានិមិត្តរូបនៃការបើកការដ្ឋានការសាងសង់អគារទាំងពីរនេះជាផ្លូវការក្រោមការប្រោសព្រំជ័យន្តោមង្គល ពីសម្តេចព្រះសុមេធាធិបតី **នន្ទ ង៉ែត** ព្រះសង្ឃនាយកនៃព្រះរាជាណាចក្រកម្ពុជា ដើម្បីសុំសិរីសួស្តី និងសុវត្ថិភាពទាំងក្នុងពេលដំណើរការសាងសង់ និងសុំសេចក្តីសុខជារៀងរហូត។

សូមបញ្ជាក់ថា ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ក៏ដូចជាមន្ទីររៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ទើបនឹងបង្កើតឡើងក្នុងនីតិកាលទី ២នៃរដ្ឋសភា ហើយទីតាំងអគារធ្វើការងារនៃក្រសួង និងមន្ទីរនេះ ជាប្រភេទសំណង់ភូមិគ្រឹះ សល់ពីសម័យសង្គមរាស្ត្រនិយម ដែលមានហេដ្ឋារចនាសម្ព័ន្ធ សំរាប់តែការស្នាក់នៅជាលក្ខណ:គ្រួសារតូចប៉ុណ្ណោះ ទើបធ្វើឱ្យអគារទីស្តីការក្រសួង និងមន្ទីរមិនអាចរ៉ាប់រងបាននូវបរិមាណមន្ត្រីដែលមានជិត ១.០០០នាក់ ឱ្យប្រមូលផ្តុំនៅជុំក្នុងអគារធ្វើការតែមួយកន្លែងបាន ពោលគឺមានអង្គភាពខ្លះស្ថិតនៅលើទីតាំងផ្សេងក្រៅពីគ្នា ដែលមិនអាចធានាបាននូវសេវាទាន់ពេលវេលា។ ដោយមើលឃើញពីភាពលំបាក និងពីតម្រូវការផ្តល់សេវាកិច្ចក្នុងវិស័យជំនាញរបស់ក្រសួង និងមន្ទីរ ដែលពីមួយថ្ងៃ ទៅមួយថ្ងៃកាន់តែរីកចំរើននោះ រាជរដ្ឋាភិបាលបានឯកភាពឱ្យស្ថាបនាឡើងវិញលើទីតាំងចាស់របស់ក្រសួង ដែលមានផ្ទៃក្រឡាជាង ២.០០០ម$^2$ ស្ថិតនៅតាមបណ្តោយមហាវិថីព្រះមុនីវង្ស នូវអគារធ្វើការថ្មី ដែលមានកំពស់ ៩ជាន់ សំរាប់ឯការទីស្តីការក្រសួង និងកំពស់ ០៧ជាន់ សំរាប់អគារមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីរាជធានីភ្នំពេញ ដោយបានប្រគល់សិទ្ធិ សាងសង់ដល់ក្រុមហ៊ុន ឃុនសៀវដេវឺឡុបមេនគ្រុប ជាអ្នករ៉ាប់រងការសាងសង់ ដែលតាមការគ្រោងទុកអគារទាំងពីរ

នឹងអាចស្ថាបនារួចជាស្ថាពរ នៅដើមត្រីមាសទី ១ នៃឆ្នាំ ២០១២។ ទន្ទឹមនឹងសំណង់ធំទាំងពីរនេះ រាជរដ្ឋាភិបាលនៅបានអនុញ្ញាត ឱ្យសាងសង់អគារធ្វើការរបស់ខ្សែបណ្ដោយក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់នៅខេត្ត និងក្រុងស្រុកខណ្ឌចំនួន ១១៦ ទៀត។